# ការសំពះដែលត្រឹមត្រូវតាមប្រពៃណី_ទំនៀមទំលាប់ខ្មែរ

សំពះគឺជាផ្នែកមួយនៃ សុជីវធម៌ សីលធម៌ និងប្រពៃណី ទំនៀមទំលាប់ខ្មែរ។ គ្រប់ខ្នាតសំពះទាំង ៥ ក្នុងការសំដែងភាពគោរព ឬ គារវកិច្ច នៅពេលជួបគ្នានោះ ខ្មែរតែងទំលាប់លើកដៃទាំងពីរ ផ្គុំ ប្រណម ជារាងផ្កាឈូកក្រពុំ ដោយចុងម្រាមផ្ទៀងទៅមុខបន្តិច ផងដែរ។ ក្នុងខ្នាតទាំង ៥ កំពស់នៃ ប្រអប់ដៃ ដែលលើកប្រណមនោះ មានកំរិតខុសគ្នា ចន្លោះចាប់ពីត្រឹមដើមទ្រូងឡើងទៅដល់ប្រជុំចិញ្ចើម។



**ការសំពះរបៀបទី១** គឺថ្វាយបង្គំចំពោះ ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ។

First Method: Men worship to the *Buddha, Dhamma* and *Sangha* (Triple Gem). It is a little different from woman.

ការគោរពថ្វាយបង្គំ គឺស្ថិតក្នុងខ្នាតទី ៤ និង ទី ៥ ដែលមាន លក្ខណៈ ខ្ពង់ខ្ពស់ ស្មើសិរ្សា ឬត្បូង គឺក្បាល។ របៀបក្រាបថ្វាយបង្គំក្នុងព្រះពុទ្ធសាសនាវិញ គេអាចហៅថា “បញ្ចប្រណម្យ ” ឬក៏ “បញ្ចាង្គប្រណម្យ ” សំដៅ ទៅលើការគោរព សំពះដោយ ៥ចំណែកនៃអង្គប្រាណគឺមានថ្ងាស ១ ដៃទាំង២ និងជង្គង់ទាំង ២។ ម្យ៉ាងវិញទៀត របៀបថ្វាយបង្គំព្រះសង្ឃនេះ មានឥរិយាបថ ផ្សេងៗគ្នា រវាងបុរស និងនារី។

The respect attitude of women worship to the Triple Gem: *Buddha, Dhamma* and *Sangha*.



ដូចគ្នា ចុងដៃហ្នឹងត្រង់ប្រជុំចិញ្ចើម ប៉ុន្តែចំពោះបុរស ត្រូវលុតជង្គង់ទាំង២ ហើយដងខ្លួនត្រង់ លើកដៃ ទាំង ២ ប្រណម្យ ដោយដាក់ចុងដៃត្រង់ប្រជុំចិញ្ចើម។ ការសំពះចំពោះព្រះសង្ឃ គឺមាន ៣ដង ។ គឺការឱនទី ១ ឱន ទី ២ គឺគ្រាន់តែឱន ហើយដាក់ដៃដល់កម្រាលទេ រហូតដល់ការឱនលើកទី ៣ ទើបគេឱនទាំងដងខ្លួន ទាំងក្បាល រហូតដល់កម្រាលតែម្តង។ នេះគឺចំពោះបុរស។ រីឯចំពោះស្ត្រីវិញ គឺមិនលុតជង្គង់ដូចបុរសទេ នារី ត្រូវអង្គុយ បត់ ជើងមកស្តាំ ផ្ទៀងខ្លួនមកឆ្វេងបន្តិច ក្រាបចុះដាក់ចុងដៃប្រណម្យ ត្រង់ប្រជុំចិញ្ចើមដូចគ្នា ហើយក្រាបថ្វាយបង្គំដងខ្លួន និងក្បាលឱ្យបាន ៣ ដងដល់កម្រាល។ គឺខុសពីបុរសត្រង់នេះឯង។” សៀវភៅរបៀបសំពះខ្មែរ បានសរសេរបង្ហាញទៀតថា ព្រះសង្ឃ មិនតម្រូវឱ្យសំពះតបទៅឧបាសក ឧបាសិកាវិញនោះឡើយ ទោះបីមានអាយុចាស់ជាង ឬ ឋានន្តរសក្តិធំ សូម្បីតែស្តេចផែនដីក៏ដោយ។ ព្រះសង្ឃ ត្រូវតបវិញដោយ ថេរដីកា ថា “ចំរើនពរ” ឬយកព្រះហស្ត មកប៉ះនឹងបុរសជាឧបាសក ឬតបដោយទឹកមុខតែប៉ុណ្ណោះ។



**របៀបសំពះទី២** គឺការសំពះ ដោយការគោរព ឬចូលគាល់ព្រះមាក្សត្រ។

Second Method: worshiping to attend the king and queen.

ការបង្ហាញការសំពះ របស់ខ្មែរនេះ ឃើញថា គឺទាំងប្រុស ទាំងស្រី គឺចលនា នៃការគោរពនេះ គឺដើងដូចគ្នា។ គឺត្រូវបញ្ឈរជង្គង់ខាងឆ្វេង ហើយលុតជង្គង់ខាងស្ដាំក្រាបផ្ទាល់ដល់កម្រាលតែម្ដង។ ហើយលើកដៃប្រណម្យឡើង ដោយដាក់ចុងត្រឹមប្រជុំចិញ្ចើម ហើយឱនចុះបន្តិច។" រីឯរបៀបថ្វាយបង្គំស្ថិតក្នុងកាលៈទេសៈទី ២ វិញ គឺជាការថ្វាយបង្គំគាល់ ដែលការសំពះនេះ ប្រព្រឹត្តទៅក្នុងរយៈពេលវេលាយូរ ក្នុងឱកាសសវនាការ ឬស្ដាប់ ព្រះរាជឱង្ការ ព្រះមហាក្សត្រ ÷ "គឺយើងត្រូវអង្គុយបត់ជើង មកខាងស្ដាំ ហើយយក កែងដៃទាំងសង្ខាងច្រត់ទៅលើក្បាលជង្គង់ទាំង ២ ដែលយើង បត់ជើងនោះ។ ដៃរបស់យើង ត្រូវលើកមកផ្គុំ ត្រង់ប្រជុំចិញ្ចើម ហើយឱនមុខចុះ។ តាមទំនៀមទំលាប់យើងគឺ ថានៅពេលក្រាបថ្វាយបង្គំគាល់ គឺយើង អត់ឱ្យងើបមុខ មើលព្រះមហាក្សត្រនោះទេ។" ប៉ុន្តែ បើតាមសៀវភៅបង្ហាញពីរបៀបសំពះខ្មែរ ក៏បានបញ្ជាក់ដែរថា ជាទូទៅសព្វថ្ងៃនេះ គេនិយមអង្គុយនៅ លើកៅអី ហើយលើកដៃសំពះ ក្នុងឱកាសថ្វាយបង្គំគាល់ព្រះមហាក្សត្រ។

ខ្នាតទី ១ គឺប្រណម្យ ដៃទាំង ២ ត្រឹម ដើមទ្រូងដោយ ចុងម្រាមដៃ ស្ថិតនៅក្រោមចង្កា ដែលជាការគោរពចំពោះមិត្តភ័ក្តិ ឬមនុស្ស មានអាយុ ឬឋានៈស្មើគ្នា។

ខ្នាតទី ២ គឺជាការសំពះ ចំពោះជន ដែលមានវ័យ ចាស់ជាង ឬមានបុណ្យ ស័ក្តិ ធំជាង ដោយកំពស់ចុងដៃ លើកប្រណម្យ ត្រឹមបបូរមាត់។ ចំពោះមាតា បិតា ជីដូន ជីតា និង គ្រូបាអាចារ្យ គឺជាការ សំពះ ធ្វើឡើង ដោយដាក់ ចុងម្រាមដៃ ដល់ត្រឹមចុង ច្រមុះ។

ការថ្វាយបង្គំ ព្រះមហាក្សត្រ គឺជាខ្នាតសំពះទី ៤ ដោយប្រណម្យដៃដាក់ដល់ប្រជុំចិញ្ចើម។
ខ្នាតសំពះទី ៤ នេះត្រូវបានគេយកទៅប្រើប្រាស់ ក្នុងការថ្វាយបង្គំ ព្រះភិក្ខុសង្ឃ ក្នុងព្រះពុទ្ធសាសនាផងដែរ ទាំងក្នុង ឥរិយាបថ ឈរ និង អង្គុយរាបស្មើនឹងកម្រាល។

រីឯខ្នាតទី ៥ ជារបៀបសំពះ ឬថ្វាយបង្គំ បួងសួង ចំពោះព្រះឥន្ទ្រ ព្រះព្រហ្ម ទេវតា ជាដើម ដោយកម្រិត ចុងដៃប្រណម្យលើកខ្ពស់ដល់ថ្ងាស។



**ការសំពះរបៀបទី៣** គឺសំពះគារវកិច្ចចំពោះមិត្តភក្តិ ដែលមានឋានៈស្មើគ្នា។

Third Method: use to express greeting to friends.

ចំពោះខ្នាតទី៣ សៀវភៅស្តីពីរបៀបសំពះខ្មែរ ដែលនិពន្ធ ឡើងដោយលោក សំសំអាង និងលោក ងួន សំអាត នៃ សមាគម វប្បធម៌ខ្មែរ បានបង្ហាញឱ្យដឹងថា គឺជាការគោរពចំពោះមិត្តភក្តិ និងមនុស្សដែលមានឋានៈ និងវ័យ ស្របាល គ្នា។ រីឯខ្នាតនៃការសំពះ គឺដៃប្រណមត្រឹមដើមទ្រូង ដោយចុងដៃស្ថិតនៅក្រោមចង្កា ហើយដើមដៃទាំងពីរដាក់ស្របអប ជាប់នឹងដងខ្លួន។ “ចំពោះការសំពះរបៀបអ្នកចាស់ជាង ឬចៅហ្វាយនាយ គឺយើងសំពះ ដោយលើកប្រណមដាក់ ម្រាមដៃ ត្រឹម បបូរមាត់ ហើយអ្នក ដែលចាស់ជាងយើង អាចលើកសំពះតប ដោយចុងដៃ ត្រឹមដើមទ្រូង។ ហើយនៅពេលសំពះ គឺយើងត្រូវឈរឱ្យត្រង់ ហើយឱន ក្បាលបន្តិច ដើម្បីជាការគួរសម។”

តាមទំនៀមទំលាប់ ខ្មែរយើងសំពះដោយលើកដៃទាំង២ផ្គុំគ្នា ជារាងផ្កាឈូកក្រពុំ ហើយ ផ្ទៀងចុងដៃ ទៅមុខបន្តិច លើកឡើងកំពស់ ចន្លោះពីដើមទ្រូង និងមុខដោយដាក់ដើមដៃទាំងពីរនៅជាប់ស្របនឹងដងខ្លួន។ យុវតី កង សុចិត្រា និស្សិតបញ្ចប់បរិញ្ញាប័ត្រ រង ផ្នែកពាណិជ្ជកម្ម ដែលជាអ្នកធ្លាប់បាន អាន សៀវភៅនេះ មួយរូប ដែរ នោះ បានឱ្យដឹងថា សៀវភៅនេះ បានសរសេរអំពីខ្នាតសំពះរបស់ខ្មែរ ដែលចែក ចេញជា ៥ ខ្នាត ហើយនៅ ពេល ណា កំរិតដៃប្រណមកាន់តែខ្ពស់ នោះទំហំ នៃការគោរពគារវកិច្ច ក៏កាន់តែធំទៅតាមនោះដែរ ។

[កេសរណ្ណីយ៉ា] “នាទីយើងចង់ឱ្យប្អូននិយាយអំពីក្បួនខ្នាតទី ១ នៃការសំពះរបស់ខ្មែរ តើជាការសំពះរបៀបណា?” [សុចិត្រា] “ចាស គេចង់និយាយអំពីការសំពះចំពោះអ្នកដែលមានឋានៈស្មើគ្នា ឬក៏វ័យ ស្មើគ្នា។ ការសំពះនេះ គេត្រូវដាក់ដៃ ប្រណមនៅលើដើមទ្រូង ឱ្យម្រាមដៃស្ថិតនៅក្រោមចង្កា។ ហើយដងខ្លួនយើងរាងឱនបន្តិច រាល់ការសំពះរបស់ខ្មែរ ខ្នាត ត្រង់ណាក៏ដោយ គឺមានការឱនបន្តិចជានិច្ច។” សៀវភៅស្តីពី “របៀបសំពះខ្មែរ ” ក៏បានសរសេរបញ្ជាក់ថា ការសំពះអាចធ្វើឡើងក្នុងឥរិយាបទ ឈរ អង្គុយ ឬ ដេកនៅលើគ្រែ ក្នុងករណីអ្នកជម្ងឺ។ ការលើកដៃសំពះ ត្រូវធ្វើឡើង ដោយយឺតៗ ទន់ភ្លន់ មិនរហ័សពេក ឬ ប្រញាប់ឡើយ។ នៅគ្រប់ខ្នាតទាំង ៥ នៃសំពះខ្មែរ ចំពោះប្រអប់ដៃត្រូវផ្គុំប្រណមជារាងផ្កាឈូកក្រពុំ ដោយដាក់ម្រាមដៃតម្រៀបឱ្យជិតគ្នា ពុំមានចន្លោះឡើយ។

Way of expressing worshiping/respecting /greeting to the Parents or old ages.

សំពះខ្នាតទី ៣ នេះ ÷ “ខ្នាតសំពះនេះ សំដៅទៅលើថា ពេលយើងបានជួបចាស់ទុំ ជីដូនជីតា ឬក៏ឪពុកម្តាយ ឬក៏គ្រូបាអាចារ្យ។ គឺ យើងត្រូវលើកដៃប្រណមគាត់ ចុងដៃត្រូវដាក់ត្រឹមច្រមុះ ហើយវាមាន លក្ខណៈ ខុសគ្នា ជាមួយការ សំពះខ្នាតទី ២ ត្រង់ថាវាមានការគោរពជាង។”



**Fourth Method: The Way of Worshipping (*Sompeas*) in Cambodian Classical Dance.**



“ការសំពះក្នុងរបាំបុរាណគឺមាន៣ផ្នែក។ទី ១ គឺយើងលុតជង្គង់ ហើយលើកដៃទាំង២ សន្ទឹមឡើងលើហើយលាដៃរួចផ្គុំ ចូលគ្នា។ ម្រាមដៃទាំង៤ពត់ងមកខាងខ្នងដៃជារបៀបផ្កាឈូករីក។ ចំពោះការសំពះ ដាក់ដៃត្រឹមដងខ្លួនគឺជាការសំពះ ចំពោះ ព្រះមហាក្សត្រ ឬអធិបតីឬអ្នកធំដែលយើងរៀបនឹង សំដែង នៅចំពោះមុខ។ ដំណាក់កាល ទី ២ គឺលើកដៃឡើង ដល់ថ្ងាស។ របៀបនេះគឺជា ការរំលឹកគុណដល់គ្រូបាអាចារ្យ ឬក៏វត្ថុស័ក្តិសិទ្ធិ ដើម្បី ជាការ បួងសួង។ ចំណែកការសំពះ របៀបទី ៣ គឺលើកដៃ ត្រឹមចុងដង្ហើម ដែលជាការសំពះ ជាទូទៅ ចំពោះទស្សនិកជនដែលបានមក មើលការ សំដែង។ និយាយរួមក្នុងរបាំ នីមួយៗ តែងតែមានការសំពះទាំង ៣ យ៉ាងនេះ។”

**របៀបសំពះទី៤** គឺសំពះក្នុងពិធីសំដែងសិល្បៈ ។





របៀបសំពះខ្មែរ គឺជាមត៌កវប្បធម៌តំណាងឱ្យអត្តសញ្ញាណជាតិដ៏សំខាន់។ឆ្លងតាមរបៀបសំពះនេះ គេអាចស្គាល់ថាជាខ្មែរជាវប្បធម៌ ប្រពៃណីរបស់ប្រទេសមួយ។ ជាងនេះទៀត គេអាចសំគាល់ ជាតិសាសន៍ខ្មែរមិនត្រឹមតែតាមរយៈការពិនិត្យមើលរបៀបសំពះ ក្នុងជីវភាព ធម្មតានេះទេតែតាមរយៈរបៀបសំពះខ្មែរក្នុងពិធីអាពាហ៍ពិពាហ៍និងក្នុងរបាំខ្មែរដែលជាពិធីទំនៀមទំលាប់និងពិធីកំសាន្តសប្បាយនិងជាកេរ្តិ៍ដំណែលជាព្រលឹងរបស់ជាតិខ្មែរជាយូរអង្វែងមកហើយនោះ ។ របៀបសំពះនៅក្នុងរបាំ មានសភាពខុសប្លែក ពីសំពះក្នុងជីវិតធម្មតា ពោលគឺ មានលក្ខណៈកែច្នៃ លំអឱ្យមានសោភ័ណភាពជាសិល្បៈ។ លក្ខណៈពិសេសនោះ គឺសិល្បករ មិនសំពះដោយប្រណម្យ ដៃ ជារាងផ្កាឈូក ក្រពុំទេ តែជាការសំពះ ជាទំរង់ផ្កាឈូករីក ដោយពត់ម្រាមដៃ ទាំងដប់ឱ្យ ង មកក្រៅទៅវិញ។

<u>របៀបសំពះទី៥</u> គឺអាពាហ៍ពិពាហ៍

**Fifth Method: The Way of Khmer Worshipping in Wedding Ceremony.**

ចំពោះ របៀបសំពះក្នុងអាពាហ៍ពិពាហ៍ គឺមានច្រើនរបៀប និងសណ្ឋានណាស់ អាស្រ័យដោយពិធីអាពាហ៍ពិពាហ៍ខ្មែរ ប្រព្រឹត្ត ឡើង ក្នុង លក្ខណៈ អឹកអធឹក និងមានរយៈ ពេលដល់ទៅ ៧ យប់ ៧ ថ្ងៃ នាសម័យដើម។ នៅក្នុងសៀវភៅនេះ វិធីសំពះផ្ទឹម ចងដៃ គឺកូនកម្លោះ និងកូនក្រមុំ ផ្គុំដៃទាំងពីរ សំពះ ហើយយកដៃ ដាក់លើខ្នើយដែលចាស់ៗ ហៅថា ក្រាបក្បាលដល់កន្ទេល។ គឺ សំពះផ្ទឹមនេះ គេហៅថាសំពះផ្ទឹម រួមខ្នើយ។សំពះត្រូវបានឃើញខ្មែរ និយមប្រើ នៅក្នុងពិធីតូចៗ ផ្សេងទៀត នាឱកាស រៀបមង្គលការ កូនប្រុស ស្រី ដូចជាសំពះ ក្នុងពិធីសូត្រមន្ត កាត់សក់ លើកជំនូន និងកាត់ខាន់ស្លាជាដើម។



